**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.គ លេខ ១០.០១៧/០៩ គ.ជ.ប.អគ្គ/ពស**

រាជធានីភ្នំពេញ ថ្ងៃទី 17 ខែតុលា ឆ្នាំ២០០៩

## ឃុំ សង្កាត់សរុបចំនួន ៥១ ដែលរងគ្រោះដោយធម្មជាតិ ត្រូវបានបន្ថែមរយៈពេល ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៩ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចបន្ថែមរយៈពេលសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ចំនួន ៥១ ដែលមានរយៈពេលបន្ថែមចាប់ពី ០៤ថ្ងៃ ០៣ថ្ងៃ និង ០២ថ្ងៃ ។ ឃុំ សង្កាត់ចំនួន ២១ ត្រូវបន្ថែមរយៈពេល ០៤ថ្ងៃ ឃុំ សង្កាត់ចំនួន ២៨ បន្ថែម ០៣ថ្ងៃ និងឃុំ សង្កាត់ចំនួន ០២ បន្ថែម ០២ថ្ងៃ ហើយការបន្ថែមរយៈពេលនេះ ចាប់អនុវត្តគិតពីថ្ងៃទី២១ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៩ ។

ឈ្មោះឃុំ សង្កាត់ដែលត្រូវបន្ថែមរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមានដូចក្នុងតារាងខាងក្រោម ៖

| ល.រ | ឈ្មោះខេត្ត | ឈ្មោះឃុំ សង្កាត់ | ចំនួនរយៈពេលបន្ថែម |
|---|---|---|---|
| ១ | បាត់ដំបង | កន្ទឺ២ | ០២ |
| | | ឈើទាល | ០២ |
| | | ត្រែង | ០៣ |
| | | ព្រៃត្រឡាច | ០៣ |
| | | មានជ័យ | ០៣ |
| | | សំឡូត | ០៣ |
| | | តាសាញ | ០៣ |
| | | ទួលតាឯក | ០៤ |
| | | ព្រែកព្រះស្តេច | ០៤ |
| | | រតនៈ | ០៤ |
| | | ចំការសំរោង | ០៤ |
| | | ស្លាកែត | ០៤ |
| | | ក្តុលដូនទាវ | ០៤ |
| | | អូរម៉ាល់ | ០៤ |
| | | វត្តគរ | ០៤ |
| | | អូរចារ | ០៤ |
| | | ស្វាយប៉ោ | ០៤ |
| | | សិរីមានជ័យ | ០៤ |
| | | ជ្រៃសីមា | ០៤ |

| | | | |
|---|---|---|---|
| ២ | **កំពង់ធំ** | ឈូក | ០៣ |
| | | គោល | ០៣ |
| | | តាំងក្រសៅ | ០៣ |
| | | ដងកាំបិត | ០៣ |
| | | ក្អែង | ០៣ |
| | | មានជ័យ | ០៣ |
| ៣ | **ក្រចេះ** | ហាន់ជ័យ | ០៣ |
| | | កញ្ជរ | ០៣ |
| | | ព្រែកសាម៉ាន់ | ០៣ |
| | | ក្រចេះ | ០៣ |
| | | ថ្មគ្រែ | ០៣ |
| | | ជ្រោយបន្ទាយ | ០៣ |
| | | កោះខ្ញែរ | ០៣ |
| ៤ | **ព្រះវិហារ** | កំពង់ស្រឡៅមួយ | ០៣ |
| | | កំពង់ស្រឡៅពីរ | ០៣ |
| ៥ | **សៀមរាប** | ទឹកវិល | ០៣ |
| | | អំពិល | ០៣ |
| | | ស្លក្រាម | ០៣ |
| | | គោកចក | ០៣ |
| | | សាលាកំរើក | ០៣ |
| | | ជ្រាវ | ០៣ |
| | | ចុងឃ្នៀស | ០៣ |
| | | សៀមរាប | ០៣ |
| ៦ | **ឧត្តរមានជ័យ** | លំទង | ០៤ |
| | | ត្រពាំងប្រិយ៍ | ០៤ |
| | | ត្រពាំងតាវ | ០៤ |
| | | បេង | ០៤ |
| | | ជើងទៀន | ០៤ |
| | | បុស្បូវ | ០៤ |
| | | កូនក្រៀល | ០៤ |
| | | សំរោង | ០៤ |
| | | អូរស្វាយ | ០៤ |

លទ្ធផលបណ្តោះអាសន្ន នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ ចុះឈ្មោះបានចំនួន **១៥៦.៣៨៤** នាក់ ស្មើនឹង **៥៥.៨០%** កែតម្រូវឈ្មោះបានចំនួន **២៧.៧៨៥** នាក់ និងលុបឈ្មោះ ចេញពីបញ្ជីបោះឆ្នោតចំនួន **៦៦.៥៥៣** នាក់ ហើយលទ្ធផលនេះ គ.ជ.ប បានទទួលពីឃុំ សង្កាត់ចំនួន ១.៥២៦ ក្នុងចំណោម ឃុំ សង្កាត់ទាំង ១.៦២១ ទូទាំងប្រទេស ។

ខណៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជិតនឹងបញ្ចប់នេះ ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប បានធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ដែលពុំទាន់បានចុះឈ្មោះ និងទើបគ្រប់អាយុបោះឆ្នោតអញ្ជើញទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតកុំបីខាននៅតាមសាលាឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ ។